# មេរៀនទី ១៤១៖
# ព្រះមានព្រះបន្ទូលទៅអេលីយ៉ាដោយសម្លេងតូចរហៀងៗ

១ ពង្សាវតាក្សត្រ ១៩៖៩ -១៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/LOphN9UpKUg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/mFN6TaC7G2E

**គោលបំណង៖** ព្រះលើកទឹកចិត្តយើង។

**ខគម្ពីរចងចាំ៖ យ៉ូស្វេ ១៖៩** *"តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយ នៅកន្លែងណា ដែលឯងទៅផង។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

២.ចូរមានកំលាំងនិងចិត្តក្លាហានចុះ https://youtu.be/Mr7oyUvG7U8

៣.ខ្ញុំអាចធ្វើបានគ្រប់ការ https://youtu.be/RAti7KCmIvM

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «គ្មានបញ្ហា»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង ឧបសគ្គ(កំណាត់ឈើ ឬអំបោស)



១. ចែកកុមារជាពីរក្រុម ហើយឲ្យពួកគេចាប់ដៃគូរពីរៗនាក់

២. ដាក់ឧបសគ្គនៅលើឥដ្ឋ ដើម្បីឲ្យកុមារលោតរំលង។

៣. ឲ្យប៉េងប៉ោងមួយទៅក្រុមទាំងពីរ ហើយឲ្យពួកគេដាក់ប៉េងប៉ោងនៅចន្លោះខ្នងរបស់ពួកគេ ហើយដើរទៅកាន់ទីជាមួយគ្នា។



៤. ប្រសិនបើពួកគេធ្វើឲ្យធ្លាក់ប៉េងប៉ោងនោះពួកគេត្រូវចាប់ផ្តើមម្តងទៀត។

៥. លេងល្បែងនេះរហូតដល់កុមារនៅក្នុងក្រុមទាំងពីរបានលេងគ្រប់គ្នា។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះតែងតែមានវត្តមាននៅក្នុងជីវិតរបស់យើង ដូច្នេះយើងត្រូវបានលើកទឹកចិត្តដោយព្រះនិងបន្តដំណើររបស់យើង ទោះបីជាយើងបរាជ័យក៏ដោយ។ គ្មានអ្វីអាចរារាំងយើងបានទេ ព្រោះព្រះតែងតែលើកទឹកចិត្តដល់យើង!

## ៤. ការណែនាំមេរៀន

ប្អូនៗនៅថ្ងៃនេះអ្នកគ្រូចង់អោយប្អូនបានធ្វើទឹកមុខតាមអ្នកគ្រូទាំងអស់គ្នា បើគ្រូធ្វើមុខក្រៀមក្រំ ប្អូនត្រូវធ្វើមុខក្រៀមក្រំទាំងអស់គ្នា គ្រូធ្វើមុខសើចយើងសើចទាំងអស់គ្នា ហាស............ គ្រូធ្វើមុខយំយើងធ្វើសំលេងយំទាំងអស់គ្នា ហ៊ិ....... ពេលគ្រូធ្វើខឹងយើងធ្វើខឹងទាំងអស់គ្នាដោយសំឡក់.....ដាក់គ្នា គ្រូធ្វើមុខសប្បាយយើងត្រូវរាំទាំងអស់គ្នា។

តើអ្នកនឹងធ្វើដូចម្តេចនៅពេលដែលអ្នកមានការក្រៀមក្រំ? តើអ្នកនឹងយំឬ? តើអ្នកខឹងឬ? ឬក៏អ្នកនឹងស្វែងរកនរណាម្នាក់ដើម្បីលើកទឹកចិត្តអ្នក? ព្រះបានចាត់មនុស្សជាច្រើនមកក្នុងជីវិតរស់នៅរបស់យើងដើម្បីលើកទឹកចិត្តយើង។ ថ្ងៃនេះយើងហ្នឹងរៀនពីបុរសម្នាក់ដែលមានការសោកសៅ នៅតែម្នាក់ឯង និងពីរប្រៀបដែលព្រះលើកទឹកចិត្តដល់គាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងដកស្រង់ចេញពីព្រះគម្ពីរ **១ ពង្សាវតាក្សត្រ**។ មនុស្សម្នាមានការខឹងសម្បាជាមួយនឹងអេលីយ៉ា។ អេលីយ៉ា មានអារម្មណ៍ថាឯកា និងនៅតែឯង។ អេលីយ៉ាបានធ្វើដំណើរ៤០ថ្ងៃ៤០យប់ ដើម្បីទៅដល់ភ្នំហោរែប ជាភ្នំនៃព្រះ។ លុះមកដល់ភ្នំហើយគាត់ក៏លូនចូលរូងភ្នំដើម្បីសម្រាក។

បន្ទាប់មកគាត់ក៏លឺព្រះបន្ទូលនៃព្រះ "អេលីយ៉ាអើយ តើធ្វើអីនៅទីនេះ?" អេលីយ៉ាបានប្រាប់ព្រះថា គាត់បានបម្រើព្រះដោយអស់ពីចិត្តនិងស្មោះត្រង់ ប៉ុន្តែជនជាតិអ៊ីស្រាអែលនៅតែបំផ្លាញអាសនា ដែលពួកគេគោរពប្រណិប័តន៍ព្រះ ហើយថែមទាំងបានសម្លាប់ហោរារបស់ព្រះទៀតផង។ គាត់បានប្រាប់ព្រះថា គាត់ជាហោរាតែម្នាក់គត់ ដែលនៅសេសសល់ ហើយពួកគេក៏ចង់សម្លាប់គាត់ដែរ។

ព្រះក៏មានបន្ទូលថា**១ ពង្សាវតាក្សត្រ១៩៖១១** "ចូរឯងចេញទៅ ឈរលើភ្នំនៅចំពោះព្រះយេហូវ៉ាចុះ នោះមើល ព្រះយេហូវ៉ាទ្រង់យាងទៅតាមទីនោះ។"

ពេលនោះមានខ្យល់បក់ខ្លាំងរហូតធ្វើឲ្យថ្មភ្នំបាក់បែកជាដុំៗ។ ប៉ុន្តែ ព្រះមិននៅក្នុងខ្យល់ទេ។ បន្ទាប់មកការរញ្ជួយដីដ៏ខ្លាំងកក្រើកដី។ ប៉ុន្តែព្រះមិននៅក្នុងការរញ្ជួយដីនោះទេ។ បន្ទាប់មកអណ្តាតភ្លើងដ៏សន្ធោសន្ធៅមួយបានឆាបឆេះលើភ្នំ។ ប៉ុន្តែព្រះមិននៅក្នុងភ្លើងទេ។ ចុងក្រោយ មានសំឡេងតូចរហៀងៗមួយបានមកដល់។

ព្រះទ្រង់គង់នៅក្នុងសម្លេងតូចរហៀងៗនោះ។ សម្លេងតូចរហៀងៗនោះបានលើកទឹកចិត្តដល់អេលីយ៉ា។ ព្រះបានប្រាប់អេលីយ៉ាថា ឯងមិននៅតែឯងទេ គឺមានមនុស្ស៧ពាន់នាក់ ដែលនៅតែស្រលាញ់ព្រះ។ ព្រះអង្គក៏បានប្រាប់អេលីយ៉ាពីអ្វីដែលគាត់ត្រូវធ្វើ នៅពេលដែលគាត់ត្រឡប់ទៅរកប្រជាជនអ៊ីស្រាអ៊ែលវិញ។ ព្រះ បន្ទូលនៃព្រះគឺពិតជាលើកទឹកចិត្តដល់លោកអេលីយ៉ាខ្លាំងណាស់។

នៅពេលដែលអេលីយ៉ាបាក់ទឹកចិត្ត ព្រះទ្រង់មិនបានមកដោយខ្យល់បក់គំហុក ការរញ្ជួយដី ឬក៏អណ្តាតភ្លើងឆាបឆេះនោះទេ។ ព្រះបានយាងមកកាន់អេលីយ៉ាតាមរយៈសម្លេងតូចរហៀងៗ ស្រាលស្រទន់ក្នុងការនិយាយលើកទឹកចិត្តមកកាន់អេលីយ៉ា។

ព្រះក៏លើកទឹកចិត្តយើងនៅពេលដែលយើងមានការភ័យខ្លាច មានជម្ងឺ ឯកា ឬក៏ពេលយើងត្រូវការជំនួយ។ ពេលខ្លះព្រះបានលើកទឹកចិត្តយើងតាមរយៈអ្នកដែលនៅជុំវិញយើង។ ព្រះអាចលើកទឹកចិត្តយើងតាមរយៈឪពុកម្តាយរបស់យើង មិត្តភក្តិរបស់យើង គ្រូបង្រៀនរបស់យើង ឬក៏អ្នកជិតខាងរបស់យើងផងដែរ។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាជនជាតិអ៊ីស្រាអ៊ែលចង់សម្លាប់ហោរាអេលីយ៉ា? *(ពីព្រោះគាត់ជាអ្នកបម្រើរបស់ព្រះ)*

២. តើមានហេតុការណ៍អ្វីខ្លះកើតឡើងមុនពេលសម្លេងតូចរហៀងៗ?
*(ខ្យល់បក់ ការរញ្ជួយដី ភ្លើងឆេះ)*

៣. តើព្រះបានមានបន្ទូលទៅកាន់អេលីយ៉ាដោយរបៀបណា? *(សម្លេងតូចរហៀងៗ)*

៤. តើព្រះបានលើកទឹកចិត្តយើងនៅពេលណាខ្លះ?

*(ភ័យខ្លាច មានជម្ងឺ ឯកា ឬក៏ពេលយើងត្រូវការជំនួយ ។ល។)*

៥. តើអ្នកអាចលើកទឹកចិត្តអ្នកដទៃបានដោយរបៀបណា? *(ធ្វើល្អ លើកទឹកចិត្ត និងឱប ។ល។)*

## ៧. ល្បែងកំសាន្ត «X / O»

សម្ភារៈដែលត្រូវការ៖ កៅអី ៩



១. ចែកកុមារជាពីរក្រុមស្មើគ្នា

២. ដាក់កៅអីជា៣ជួរ (គម្លាត១ម៉ែត្រពីគ្នា)

៣. កុមារត្រូវឈរចម្ងាយ ៣ម៉ែត្រពីកៅអី

៤. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទាំងអស់ត្រូវរត់ទៅអង្គុយលើកៅអីនោះ។

៥. ក្រុមណាដែលអាចអង្គុយជា “X/O” បាន ពួកគេនឹងឈ្នះល្បែងនេះ។ ក្រុមដែលឈ្នះនឹងលើកទឹកចិត្តដល់ក្រុមដែលចាញ់ “អ្នកធ្វើបានល្អហើយ”។

៦. បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់ៗគ្នាបានលេងល្បែងនេះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាព្រះដែលទ្រង់តែងតែលើកទឹកចិត្តដល់យើង ដូច្នេះយើងត្រូវចេះលើកចិត្តដល់គ្នាទៅវិញទៅមកដែរ។

## ៨. ខគម្ពីរចងចាំ

**យ៉ូស្វេ ១៖៩** *“តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្ត ក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជា មួយ នៅកន្លែងណា ដែលឯងទៅផង។”*

## ៩. ហត្ថកម្ម «តើព្រះមានបន្ទូលទៅកាន់អេលីយ៉ាដោយរប្រៀបណា?»

សម្ភារៈដែលត្រូវការ៖ ក្រដាសហត្ថកម្ម និងកូល័រ




១. សូមព្រីនក្រដាសហត្ថកម្មនៅទំព័រខាងក្រោម សម្រាប់កុមារគ្រប់ៗគ្នា។

២. ឲ្យកុមារផាត់ពណ៌លើរូបភាពទាំងនោះ

៣. នៅពេលដែលកុមារផាត់ពណ៌រួច សូមឲ្យកុមារគូសរង្វង់ជុំវិញរបៀប ដែលព្រះមានបន្ទូលមកកាន់អេលីយ៉ា។ កុមារគ្រប់គ្នាត្រូវគូសរង្វង់ជុំវិញពាក្យ “សម្លេងតូចរហៀងៗ”។

៤. សូមពន្យល់កុមារថា ព្រះតែងតែលើកទឹកចិត្តដល់យើង។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលព្រះយេស៊ូវដឹកនាំជីវិតយើង យើងមិនដែលនៅម្នាក់ឯងទេ។ សូម្បីតែពេលយើងបាក់ទឹកចិត្ត ឬឯកោក៏ដោយ យើងអាចជួបប្រទះនឹងវត្តមានរបស់ទ្រង់–និងការគាំទ្រ និងការលើកទឹកចិត្តពីគ្រិស្តបរិស័ទផ្សេងទៀត។ សូមគិតអំពីពេលវេលាដែលអ្នកមានអារម្មណ៍ថា ត្រូវបានបោះបង់ចោលដោយព្រះ ឬដោយមនុស្ស។ តើអ្នកបានទទួលកម្លាំងពីព្រះ ឬពីមិត្តភ័ក្តិក្នុងអំឡុងពេលពិបាកចិត្តនេះដែរឬទេ? ដូចអេលីយ៉ាដែរ យើងតែងតែទទួលបានការគាំទ្រពីព្រះជាទីស្រឡាញ់។ តើអ្នកនឹងផ្តល់កម្លាំងចិត្ត ដល់មិត្តភក្តិដែលជួបការលំបាកក្នុងសប្តាហ៍នេះដោយរបៀបណា?

# តើព្រះមានបន្ទូលទៅកាន់អេលីយ៉ាដោយរបៀបណា?

ខ្យល់បក់គំហុក ?



ការរញ្ជួយដី ?



អណ្ដាតភ្លើង ?



សម្លេងតូចរហៀងៗ ?

